**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

លេខៈ ២០៦ កប/ប្រ.ក

រាជធានីភ្នំពេញ, ថ្ងៃទី ២២ ខែ សីហា ឆ្នាំ២០០៧

# ប្រកាស

## ស្តីពី

## ការឈប់បុណ្យដែលត្រូវមានប្រាក់ឈ្នួល ប្រចាំឆ្នាំ២០០៨

**រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រម លេខ នស/រកម/០៧០៤/០០១ ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ២០០៤ ដែលប្រកាសឱ្យប្រើច្បាប់រដ្ឋធម្មនុញ្ញ សំដៅធានាដំណើរការជាប្រក្រតីនៃស្ថាប័នជាតិ
-បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
-បានឃើញព្រះរាជក្រមលេខ ជស/រកម/០៣៩៧/០១ ចុះថ្ងៃទី ១៣ ខែ មីនា ឆ្នាំ១៩៩៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការងារ
-បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៥/០០៣ ចុះថ្ងៃទី ១៧ ខែ មករា ឆ្នាំ២០០៥ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
-បានឃើញអនុក្រឹត្យលេខ ៥២ អនក្រ/បក. ចុះថ្ងៃទី ០១ ខែ មេសា ឆ្នាំ២០០៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
-បានឃើញអនុក្រឹត្យលេខ ៩៣ អនក្រ/បក. ចុះថ្ងៃទី ០៣ ខែ សីហា ឆ្នាំ២០០៧ ស្តីពីប្រតិទិនឈប់សំរាកការងាររបស់មន្ត្រីរាជការ និយោជិត កម្មករ ប្រចាំឆ្នាំ២០០៨

## ស ម្រេ ច

**ប្រការ១.-** ថ្ងៃបុណ្យដែលត្រូវឈប់ ហើយមានប្រាក់ឈ្នួលនៅ ឆ្នាំ២០០៨ ដោយត្រូវអនុញ្ញាតឱ្យកម្មករនិយោជិត នៃសហគ្រាស គ្រឹះស្ថានទាំងអស់ ដែលមានចែងក្នុងមាត្រា ១ នៃច្បាប់ស្តីពីការងារ បានឈប់សម្រាកការងារដោយមានប្រាក់ឈ្នួល តាមការកំណត់ដូចតទៅ:

-បុណ្យទិវាចូលឆ្នាំសកលចំនួនមួយថ្ងៃ គឺថ្ងៃទី ០១ ខែ មករា

-បុណ្យទិវាជ័យជំនះលើរបបប្រល័យពូជសាសន៍ចំនួនមួយថ្ងៃ គឺថ្ងៃទី ០៧ ខែ មករា

-បុណ្យមាឃបូជាចំនួនមួយថ្ងៃ គឺថ្ងៃទី ២១ ខែ កុម្ភៈ

-បុណ្យទិវានារីអន្តរជាតិចំនួនមួយថ្ងៃ គឺថ្ងៃទី ០៨ ខែ មីនា

-បុណ្យចូលឆ្នាំខ្មែរប្រពៃណីជាតិចំនួនបីថ្ងៃ គឺថ្ងៃទី ១៤-១៥ និងថ្ងៃទី ១៦ ខែ មេសា ជំនួសថ្ងៃទី ១៣ ខែ មេសា ដែលចំថ្ងៃអាទិត្យ

-បុណ្យទិវាពលកម្មអន្តរជាតិចំនួនមួយថ្ងៃ គឺថ្ងៃទី ០១ ខែ ឧសភា

-ព្រះរាជពិធីបុណ្យចម្រើនព្រះជន្ម ព្រះករុណាព្រះបាទសម្តេច ព្រះបរមនាថ **នរោត្តមសីហមុនី** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ចំនួនបីថ្ងៃ គឺថ្ងៃទី ១៣-១៤ និងថ្ងៃទី ១៥ ខែ ឧសភា

-បុណ្យវិសាខបូជាចំនួនមួយថ្ងៃ គឺថ្ងៃទី ១៩ ខែ ឧសភា

-ព្រះរាជពិធីបុណ្យច្រត់ព្រះនង្គ័លចំនួនមួយថ្ងៃ គឺថ្ងៃទី ២៣ ខែ ឧសភា

-ព្រះរាជពិធីបុណ្យចំរើនព្រះជន្មសម្តេចព្រះមហាក្សត្រីព្រះវររាជមាតា **នរោត្តមមុនីនាថ សីហនុ** ចំនួនមួយថ្ងៃ គឺថ្ងៃទី ១៨ ខែ មិថុនា

-បុណ្យទិវាប្រកាសរដ្ឋធម្មនុញ្ញចំនួនមួយថ្ងៃ គឺថ្ងៃទី ២៤ ខែ កញ្ញា

-បុណ្យភ្ជុំបិណ្ឌចំនួនបីថ្ងៃ គឺថ្ងៃទី ២៩-៣០ ខែ កញ្ញា និងថ្ងៃទី ០១ ខែ តុលា ជំនួសថ្ងៃទី ២៨ ខែ កញ្ញា ដែលចំថ្ងៃអាទិត្យ

-ព្រះរាជពិធីគ្រងរាជសម្បត្តិរបស់ព្រះករុណា ព្រះបាទសម្តេចបរមនាថ **នរោត្តមសីហមុនី** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ចំនួនមួយថ្ងៃ គឺថ្ងៃទី ២៩ ខែ តុលា

-ព្រះរាជពិធីបុណ្យចំរើនព្រះជន្ម ព្រះវររាជបិតា ព្រះបាទសម្តេចព្រះ **នរោត្តមសីហនុ** ចំនួនមួយថ្ងៃ គឺថ្ងៃទី ៣១ ខែ តុលា

-បុណ្យឯករាជ្យជាតិចំនួនមួយថ្ងៃ គឺថ្ងៃទី ១០ ខែ វិច្ឆិកា ជំនួសថ្ងៃទី ០៩ ខែ វិច្ឆិកា ដែលចំថ្ងៃអាទិត្យ

-ព្រះរាជពិធីបុណ្យអុំទូក បណ្តែតប្រទីប សំពះព្រះខែ និងអកអំបុក ចំនួនបីថ្ងៃ គឺថ្ងៃទី ១១-១២-១៣ ខែ វិច្ឆិកា

-បុណ្យទិវាសិទ្ធិមនុស្សអន្តរជាតិ ចំនួនមួយថ្ងៃ គឺថ្ងៃទី ១០ ខែ ធ្នូ ។

**ប្រការ២.-** ក្រៅពីថ្ងៃបុណ្យដូចមានចែងក្នុងប្រការ ១ ខាងលើ តាមគោលការណ៍ដែលមានចែងក្នុងមាត្រា១៤៧ នៃនៃច្បាប់ស្តីពីការងារ ត្រូវឱ្យឈប់នៅថ្ងៃអាទិត្យសំរាប់កម្មករនិយោជិត ទាំងអស់ ។

**ប្រការ៣.-** ប្រកាសរបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ លេខ ៧៩៥ កកបវ. ចុះថ្ងៃទី ០៧ ខែ ធ្នូ ឆ្នាំ២០០៦ ត្រូវចាត់ទុកជានិរាករណ៍ ។

**ប្រការ៤.-** ប្រកាសនេះ មានប្រសិទ្ធិភាពអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រដ្ឋមន្ត្រី

**វង្ស សុត**

**ចម្លងជូន:**
- -អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- -អគ្គលេខាធិការដ្ឋានរដ្ឋសភា
- -ខុទ្ទកាល័យ សម្តេចនាយករដ្ឋមន្ត្រី
- -ទីស្តីការគណៈរដ្ឋមន្ត្រី
- -ក្រសួងពាក់ព័ន្ធ

  "ដើម្បីជូនជ្រាប"
- -គ្រប់មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ខេត្ត-ក្រុង "ដើម្បីផ្សព្វផ្សាយ-អនុវត្ត"
- -គ្រប់សមាគមនិយោជក
- -គ្រប់សហព័ន្ធសហជីព

  "ដើម្បីជ្រាប- អនុវត្ត"
- -កាលប្បវត្តិ-ឯកសារ